# ការសំភាសន៍របស់អ៊ុំប្រុស សេង ខុន

កៈ  អ្នកដែរសំភាសន៍គេ ជាងស៊ីអ៊ារ ខៈ  អ្នកដែរអោយគេសំភាសន៍ សេង ខុន

<u>ការសង្ខេបប្រវត្តិរបស់អ៊ុំប្រុស សេង ខុន</u>

អ៊ុំប្រុស សេង ខុន មានអាយុ84ឆ្នាំ នៅក្នុងឆ្នាំ2018 អ៊ុំប្រុស សេង ខុន មានភេទប្រុសអ៊ុំប្រុស សេង ខុន មានទីលំនៅបច្ចុប្បន្ននៅផ្លូវរ៉ារទេះភ្លើង ភូមិ15 សង្កាត់ទឹកល្អក់2 ខ័ណ្ឌទួលគោក នៅរាជធានីភ្នំពេញ។

កៈ  ចឹងជាដំបូងខ្ញុំសូមអរគុណច្រើនអ៊ុំដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់អ៊ុំ ហើយការសំភាសន៍ នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីទុកអោយកូនចៅ ជំនាន់ក្រោយៗពួកគាត់បានស្គាល់ពីប្រវត្តិរបស់ឳពុកម្តាយ នឹងប្រវត្តិរបស់ដូចតា ចឹងនៅពេលដែរខ្ញុំបាន សំភាសន៍អ៊ុំហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមាន ឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសអ៊ុំ ចឹងតើអ៊ុំយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ មួយនេះទៅក្នុងវេបសាយរបស់សាលាដែរទេអ៊ុំ?

ខៈ  បាទ!!!!

កៈ  ចឹងសំរាប់ខ្ញុំជាអ្នកដែរសំភាសន៍អ៊ុំខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ ហើយថ្ងៃខែដែរការសំភាសន៍មួយនេះត្រូវបាន ធ្វើឡើងនៅថ្ងៃទី19 ខែ3 ឆ្នាំ2018 ចឹងសំរាប់អ៊ុំខ្ញុំសំភាសន៍អ៊ុំនៅផ្លូវ?

ខៈ  នៅផ្លូវរ៉ារទេះភ្លើង

កៈ  នៅផ្លូវរ៉ារទេះភ្លើង នៅភូមិអីគេដែរបង?

ខៈ  នៅនឹងនៅភូមិ15បើមិនភូមិ15ក៏ភូមិ16ដែរចង់វគ្គវាយូរដែរហើយនឹង

កៈ  នៅភូមិទី15ណាបង ប៉ុន្តែសង្កាត់អីគេដែរបង?

ខ៖ នៅសង្កាត់ទឹកល្អក់2 នឹង

ក៖ នៅសង្កាត់ទឹកល្អក់2 ខ័ណ្ឌទួលគោក នៅរាជធានីភ្នំពេញ

ខ៖ នៅយូរហើយប៉ុន្តែចង់ភ្លេច

ក៖ ចឹងសំរាបអ៊ុំមានឈ្មោះពេញនឹងឈ្មោះអីគេដែរអ៊ុំ?

ខ៖ មានឈ្មោះ សេង ខុន

ក៖ ឈ្មោះសេង ខុនហោសអ៊ុំ ចុះមានឈ្មោះហៅក្រៅទេអ៊ុំ?

ខ៖ អត់មានទេឈ្មោះមានតែមួយនឹងម្ដាយឪពុករបស់ខ្ញុំដាក់អោយនឹង

ក៖ ចុះតាំងពីក្មេងនឹងធ្លាប់មាននរណាហៅឈ្មោះអ៊ុំអីឈ្មោះផ្សេងដែរទេ?

ខ៖ អត់មានទេ

ក៖ ចឹងអត់ទេណាអ៊ុំមានតែឈ្មោះមួយនឹងទេណាអ៊ុំ?

ខ៖ បាទមានតែមួយនឹង

ក៖ ចឹងសំរាប់អ៊ុំសព្វថ្ងៃនឹងអ៊ុំអាយុប៉ុន្មានដែរអ៊ុំ?

ខ៖ ខ្ញុំអាយុ84ឆ្នាំ

ក៖ អ៊ុំអាយុ84ឆ្នាំ ចុះអ៊ុំកើតនៅថ្ងៃខែឆ្នាំណាអ៊ុំមានចងចាំទេ?

ខ៖ កើតនៅឆ្នាំ1934

ក៖ នៅឆ្នាំ1934 ចុះថ្ងៃខែអ៊ុំមានចងចាំទេអ៊ុំ?

ខ៖ នៅថ្ងៃអង្គារ៏ ខែកត្តិក នៅម៉ោង6

ក៖ អូ៎!ចុះនៅខែបារាំងហាសអ៊ុំនៅខែអីគេដែរអ៊ុំ?

ខ៖ នេះខែបារាំងនឹងអត់ដឹងទេអត់ចងចាំដែរនឹង

ក៖ ដូចជាខែ8ទៅខែ9 រឺដូចជាខែ7 ទៅខែ8អីចឹងហាសអ៊ុំ?

ខ៖ ចុះគេសំភាសន៍ចឹងគេសំភាសន៍ពីរឿងអីគេដែរ?

កៈ  សំភាសន៍ពីប្រវត្តិរបស់គាត់នឹង

ខៈ  អូ៎!សំភាសន៍ពីប្រវត្តិគេចង់ដឹងរឿងប្រវត្តិតាំងពីដើមនឹងមក

កៈ  បាទដូចថាធ្លាប់មានបញ្ហាអីគេខ្លះដែរចឹងហាស ចុះឆ្នាំច័ន្ទគតិលក្ខណៈថាឆ្នាំជូត ឆ្លូវ ខាល ថោះអី ហាសអ៊ុំចងចាំទេអ៊ុំឆ្នាំអីគេដែរ?

ខៈ  អ៊ុំឆ្នាំឆ្លូវនឹង

កៈ  អូ៎!អ៊ុំឆ្នាំឆ្លូវណាអ៊ុំ ចុះទីកន្លែងកំណើតរបស់អ៊ុំនឹងអ៊ុំកើតនៅណាដែរអ៊ុំ?

ខៈ  កើតនៅបឹងត្របែកនឹង

កៈ  កើតនៅបឹងត្របែកប៉ុន្តែនៅភូមិអី ឃុំអីគេដែរអ៊ុំ?

ខៈ

នៅបឹងត្របែកតាំងពីលុនណុលគេទំលាក់សម្តេចនឹងកំណើតកើតជានៅណុងតែម្តងនឹង

កៈ  បាទអ៊ុំបាទ?

ខៈ  ប៉ុន្តែអត់សូវចេងចាំ

កៈ  នៅបឹងត្របែកបើតាមខ្ញុំដឹងនឹងដូចជា

ខៈ  នៅកន្លែងលូទឹកស្អុយនោះនឹង

កៈ  អូ៎!នៅកន្លែងលូទឹកស្អុយនឹងបាទ?

ខៈ  នៅលូទឹកស្អុយមកពីចំការដូងមកនឹង

កៈ  នៅសង្កាត់បឹងត្របែក នៅខ័ណ្ឌចំការមនណាអ៊ុំ?

ខៈ  បាទនឹងហើយនឹង

កៈ  បាទនៅរាជធានីភ្នំពេញ ចុះអ៊ុំមានបងប្អូនចំនួនប៉ុន្មាននាក់ដែរអ៊ុំ?

ខៈ  ហោ៎!ខ្ញុំមានបងប្អូនច្រើនដែរនឹងក្មួយ

កៈ  ចុះមានប៉ុន្មាននាក់ដែរទៅអ៊ុំ?

ខះ  ជីដូននឹងគ្រាន់តែជីដូននឹងមាន3 នឹងជីតានឹង3 ហើយនឹងឪពុកម្ដាយ

កះ  ប៉ុន្តែបងប្អូនបង្កើតរបស់អ៊ុំហាស?

ខះ  បងប្អូនមានច្រើនដែរប៉ុន្តែគ្រាន់តែអត់ចងចាំអស់ទេ

កះ  ប៉ុន្តែអ៊ុំអាចចងចាំនៅអ្វីដែរអ៊ុំគិតថាអ៊ុំចងចាំឈ្មោះពួកគាត់ដែរទេ មានឈ្មោះអីគេខ្លះដែរទៅអ៊ុំ?

ខះ  ឈ្មោះនឹងបើឈ្មោះខាងជីដូនជីតាឪពុកម្ដាយរបស់ខ្ញុំនឹងឈ្មោះសុទ្ធតែ

កះ  អត់ទេបងប្អូនឈ្មោះពួកគាត់តែម្ដងនឹងហាស?

ខះ  បងប្អូនបង្កើតហោសមើលបងប្អូនបង្កើតនឹងមានឈ្មោះខុន ឈ្មោះសុន ឈ្មោះខុននឹងខ្ញុំ សុន នឹងខុន អើយ

កះ  អ៊ុំមានចងចាំអត់អ៊ុំ?

ខះ  អត់ចងចាំទេ

កះ  អូ៎!អត់អីទេអ៊ុំចឹងហោស?

ខះ  បងប្អូនមានតែ3នាក់ទេដែរជាបងប្អូនបង្កើតនឹង

កះ  អូ៎!ចឹងទេហោសអ៊ុំ?

ខះ  ប៉ុន្តែបើឪពុកម្ដាយបានច្រើននឹងជីដូនជីតាមានច្រើន

កះ  ប៉ុន្តែអ៊ុំជាកូនទីប៉ុន្មានដែរអ៊ុំ?

ខះ  ខ្ញុំជាកូនទៅមួយ

កះ  ប៉ុន្តែបងប្អូនរបស់អ៊ុំនឹងមានប្រុសទាំងអស់រឺមួយក៏ប្រុសខ្លះស្រីខ្លះដែរអ៊ុំ?

ខះ  អូ៎!ច្រើនណាស់អត់មានចងចាំទេ

កះ  អូ៎!ចឹងហោសអ៊ុំ
ចុះអ៊ុំមានចងចាំថាកាលពីនៅក្មេងនឹងអ៊ុំមានធ្លាប់លេងអីជាមួយបងប្អូនរស់អ៊ុំដែរទេ ដូចថាលេងឡឹកបាយឡ រឺមួយក៏លេងបិទពួនអីចឹងហាស?

ខ៖ អត់ទេតាំងពីតូចនឹងមកមិនចេះដើរលេងអីទេពីព្រោះម្ដាយឪពុកនឹងក្រ ដើររកស៊ីចិញ្ចឹមម្ដាយឪពុក នឹង

ក៖ ប៉ុន្តែយើងធ្លាប់ទៅស្រែអីជាមួយគ្នាដែរអត់អ៊ុំ?

ខ៖ បាទថាម៉េច?

ក៖ មានធ្លាប់ទៅស្រែអីជាមួយគ្នាដែរអត់អ៊ុំ?

ខ៖ ស្រែនឹងកាលណុងនៅបឹងត្របែកនឹងអត់មានស្រែទេ

ក៖ អត់មានទេហោសអ៊ុំ ចុះអ៊ុំកាលពីនៅតូចៗៗនឹងអ៊ុំធ្វើអីគេដែរទៅចឹង?

ខ៖ ខ្ញុំនឹងលក់នំប៉័ង លក់លាសហាល លក់ពងទាកូន

ក៖ អូ៎!ចឹងហោសអ៊ុំ?

ខ៖ លក់ដល់ខែស្វាយនឹងត្រូវទូលស្វាយលក់

ក៖ ប៉ុន្តែកាលពីជំនាន់ណុងនៅឆ្នាំប៉ុន្មានដែរអ៊ុំ?

ខ៖ កាលណុងជំនានមើលនៅជំនាន់លុនណុលនឹង

ក៖ នៅជំនាន់លុនណុលណអ៊ុំ?

ខ៖ បាទលុនណុលបានទំលាក់សម្ដេចសីហនុទៅខ្ញុំក៏គេចាប់យកទៅធ្វើជាទាហ៊ាននឹង

ក៖ អូ៎!គេបានចាប់អ៊ុំយកទៅធ្វើជាទាហ៊ានហោសអ៊ុំ?

ខ៖ បាទទាហ៊ានស៊ីដំបូងបាន3ខែ

ក៖ ប៉ុន្តែចង់និយាយថាកាលពីនៅឆ្នាំសាមជាងហាសអ៊ុំដូចជាអ៊ុំកើតនៅឆ្នាំ1937ណអ៊ុំ?

ខ៖ នៅឆ្នាំ1934

ក៖ ចុះកំឡុងពេលដែរនៅឆ្នាំ1935ទៅឆ្នាំ1936 នឹងឆ្នាំ1937-1938រឺឆ្នាំ1940នឹងអ៊ុំមានបានធ្វើអីទៅ កាលពីនៅក្មេងៗៗប៉ុនៗនេះអីហាស?

ខ៖ នៅតូចនឹងគ្មានទាន់បានធ្វើអីផងនឹង

កៈ ចឹងអ៊ុំនៅដើរលេងនៅឡើយទេណាអ៊ុំ?

ខៈ បាទនឹងហើយចឹង

កៈ ប៉ុន្តែអ៊ុំនៅដើរលេងជាមួយបងប្អូនរបស់អ៊ុំនឹងអ៊ុំធ្វើអីគេខ្លះដែរទៅអ៊ុំ?

ខៈ
ដើរលេងជាមួយអ្នកជិតខាងនឹងដើរលេងនៅបឹងត្របែកនឹងដើរលេងជាមួយអ្នកជិតៗនឹងកាលនៅ តូចៗៗនឹងដើរលេងជាមួយគ្នា

កៈ អូ៎!ប៉ុន្តែភាគច្រើននឹងគេលេងអីគេដែរអ៊ុំ?

ខៈ បាទ?

កៈ កាលពីជំនាន់ណុងគេលេងអីគេដែរទៅអ៊ុំ?

ខៈ គេលេងច្រើនតែបាញ់កូនឃ្លី

កៈ មានបាញ់កូនឃ្លីនឹងគប់ឈូង អីចឹងហាសអ៊ុំ?

ខៈ បាទនឹងលេងអានឹងបោះលូអីគេនឹងគេដាក់ម្ខាងមួយនឹង

កៈ ចុះគេមានលេងបាយខំអីលេងទេអ៊ុំ?

ខៈ បាទបាយខំនឹងគេលេងដែរ

កៈ ចឹងគេលេងល្បែងក្មេងៗពីមុននឹងមែនទេអ៊ុំ?

ខៈ បាទនឹងហើយប៉ុន្តែជាពិសេសនឹងលេងបាញ់កូនឃ្លីនឹងតែម្តងនឹង

កៈ បាទអ៊ុំប៉ុន្តែភាគច្រើននឹងអ៊ុំចូលចិត្តលេងអីគេដែរជាមួយបងប្អូនរបស់អ៊ុំ?

ខៈ លេងបាញ់កូនឃ្លីនឹង

កៈ អូ៎!លេងបាញ់កូនឃ្លីណាអ៊ុំ ចុះបងប្អូនរបស់អ៊ុំនឹងសព្វថ្ងៃនឹងគាត់នៅណាដែរអ៊ុំ?

ខៈ គាត់ស្លាប់អស់រលីងនឹង

កៈ ចឹងគាត់ស្លាប់អស់ហើយណាអ៊ុំ?

ខ៖  បាទស្លាប់អស់ហើយ

ក៖  អូ៎!បាទចឹងនៅតែអ៊ុំមួយទេ?

ខ៖  បាទនៅតែខ្ញុំមួយនឹង

ក៖  អូ៎!ចុះឪពុករបស់អ៊ុំនឹងគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខ៖  គាត់ឈ្មោះសេង ខុន

ក៖  អ៊ុំហោសឈ្មោះសេងខុន ចុះឪពុកវិញ?

ខ៖  ឪពុករបស់ខ្ញុំនឹងឈ្មោះអ៊ូ សេង ហើយខ្ញុំឈ្មោះសេង ខុន

ក៖  អូ៎!គាត់មានឈ្មោះអ៊ូ សេងណាអ៊ុំ ចុះម្តាយរបស់អ៊ុំមានឈ្មោះអីគេដែរទៅអ៊ុំ?

ខ៖  គាត់មានឈ្មោះនាង សឿន

ក៖  គាត់ឈ្មោះនាង សឿនណាអ៊ុំ
ចុះឪពុករបស់អ៊ុំនឹងបើដល់សព្វថ្ងៃនឹងប្រហែលជាគាត់អាយុប៉ុន្មានដែរ អ៊ុំមានចងចាំទេ?

ខ៖  អត់ស្គាល់ទេគាត់អាយុច្រើនដែរហើយនឹង
ចុះបើខ្ញុំអាយុប៉ែតជាហើយចឹងបើគាត់នៅនឹងអាយុមួយរយជាងហើយនឹង

ក៖  ចឹងខ្ទង់មួយរយជាងហើយនអ៊ុំ?

ខ៖  នឹងហើយខ្ទង់មួយរយនឹងទៅមួយរយជាងហើយនឹង

ក៖  បាទចុះម្តាយរបស់អ៊ុំអាយុដូចគ្នា?

ខ៖ បាទប្រហែលគ្នាម្តាយរបស់ខ្ញុំនឹងប្អូនឪពុករបស់ខ្ញុំនឹង

ក៖  ប្រហែលជាខុសគ្នាប៉ុន្មានឆ្នាំដែរទៅអ៊ុំ?

ខ៖  ប្រហែលជាខ្ទង់5ឆ្នាំអីនឹង

ក៖  បាទអ៊ុំចឹងឪពុករបស់អ៊ុំនឹងអ៊ុំមានដឹងថាគាត់កើតនៅណាដែរទេអ៊ុំ
ដូចថានៅខេត្តណាអីទេ?

ខ៖  មិនដឹងថាកើតនៅណាដែរផងគាត់មិនបានប្រាប់ទេនឹង ឪពុករបស់ខ្ញុំនឹងកាលពីប្រវត្តិរបស់គាត់នឹង ក៏ធ្វើជាទាហ៊ានដែរតើ!

ក៖  ចឹងគាត់ធ្វើជាទាហ៊ានដែរណអ៊ុំ?

ខ៖  បាទនឹងហើយ

ក៖  បាទចុះម្ដាយរបស់អ៊ុំពីប្រវត្តិរបស់គាត់នឹងអ៊ុំមានដឹងទេ?

ខ៖  ម្ដាយរបស់ខ្ញុំនឹងគាត់កើតនៅភ្នំពេញដែរនឹង

ក៖  គាត់កើតនៅភ្នំពេញនឹងកើតនៅបឹងត្របែកនឹងតែម្ដងហោសអ៊ុំ?

ខ៖  បាទៗនៅកើតនៅណុង

ក៖  អូ៎!បាទអ៊ុំ ចុះឪពុករបស់អ៊ុំកាលពីគាត់នៅរស់នឹងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរអ៊ុំ គាត់រកស៊ីអីគេដែរទៅអ៊ុំ?

ខ៖  គាត់ជាជាងអាឈើនឹង

ក៖  គាត់ជាជាងអាឈើទេណអ៊ុំ ចុះកាត់ធ្វើជាជាងអាឈើរឺមួយក៏គាត់ធ្វើអីផ្សេងទៀតដែរអ៊ុំ?

ខ៖  គាត់ធ្វើតែអាឈើនឹងតែម្ដងនឹង អាឈើហ៊ុបយើងអាធំៗនឹងហាស

ក៖  អូ៎!បាទអ៊ុំចឹង?

ខ៖  ដល់ពេលដែរក្រោយមកនឹងបានគេចាប់យកទៅធ្វើជាទាហ៊ាននឹង

ក៖  អូ៎!ចុះឪពុករបស់អ៊ុំនឹងគាត់ដូចជាកាចរឺមួយក៏ស្លូតដែរអ៊ុំ?

ខ៖  ឪពុករបស់ខ្ញុំនឹងគាត់ស្លូតណាស់

ក៖  គាត់ស្លូតណអ៊ុំ ចុះម្ដាយរបស់អ៊ុំវិញគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរអ៊ុំ?

ខ៖  ម្ដាយនឹងគាត់រកស៊ីលក់អីតាមធម្មតានឹងមានលក់លាសហាលមានអីចឹងទៅ

ក៖  អូ៎!ចុះគាត់ជាមនុស្សស្លូតរឺមួយក៏កាចដែរអ៊ុំ?

ខ៖  និយាយទៅបើគិតពីអ្នកទាំងពីរនឹងស្លូតទាំងអស់នឹង

ក៖  ចឹងហោសអ៊ុំ
ចុះអ៊ុំមានចងចាំសាច់រឿអីកាលពីអ៊ុំនៅក្មេងៗនឹងកាលពីនៅជាមួយគាត់ហាស
អ៊ុំធ្លាប់បានធ្វើអីគេខ្លះដែរជាមួយគាត់ដែរទេ?

ខ៖  ចងចាំរឿងកាលពីនៅវ័យកុមារនៅឡើយនឹងឪពុកម្ដាយរបស់ខ្ញុំនឹងគាត់ក្រ

ក៖  អូ!បាទអ៊ុំបាទ?

ខ៖  ហើយពេលដែរខ្ញុំធំឡើងដឹងក្ដីនឹងមកខ្ញុំជួយលក់នំប៉័ងៗដាក់ស្ករសហោស
ហើយលក់លាសហាល អីនឹងលក់ពងទាកូនអីចឹងទៅ

ក៖  បាទអ៊ុំចឹងទេ?

ខ៖
បាទហើយគាត់ក៏លក់លាសហាលដែរទៅហើយគាត់ស្រុះហើយគាត់ហាលដែរចឹងទៅហើ
យគាត់ អោយខ្ញុំទូលដើរលក់

ក៖  អូ!ចឹងហោសអ៊ុំនឹងជាអនុស្សាវរីយ៍ដែរជាប្រវត្តិអ៊ុំនៅជាមួយម្ដាយរបស់អ៊ុំណាអ៊ុំ?

ខ៖  បាទនឹងហើយចឹង

ក៖  ចុះឪពុករបស់អ៊ុំនឹងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងនឹងទៅអ៊ុំដែរទេ?

ខ៖  ទេរឿងគាត់នឹងខ្ញុំដឹងក្ដីឡើងនឹងមកខ្ញុំឃើញតែគាត់អាឈើមកនឹង ចិញ្ចឹមឪពុកម្ដាយ
នឹងចិញ្ចឹមខ្ញុំនឹងម្ដាយរបស់ខ្ញុំនឹងហាស

ក៖  ចឹងហោសអ៊ុំឧទាហរណ៍ថាកាលពីនៅក្មេងនឹងគាត់ធ្វើបានធ្វើអីគេខ្លះដែរ
ហើយគាត់បានរកស៊ីអីគេ ខ្លះដែរ?

ខ៖  និយាយទៅគាត់អាតែឈើនឹង

ក៖  និយាយរួមនឹងតាំងពីក្មេងរហូតនឹងតែម្ដង?

ខ៖  បាទនឹងធ្វើតែចឹង
តាំងពីកំលោះនឹងគាត់អាតែឈើរហូតទាល់តែជួបម្ដាយរបស់ខ្ញុំនឹងបាទ

កៈ  បាទអ៊ុំចឹង
ចុះម្ដាយរបស់អ៊ុំនឹងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិរបស់គាត់កាលពីគាត់នៅក្មេងនឹងទៅអ៊ុំដែរទេអ៊ុំ?

ខៈ  អត់មានដែរទេ

កៈ  ចឹងអត់មានដែរប្រាប់ទេណាអ៊ុំ?

ខៈ  បាទៗៗអត់ទេ

កៈ  អូ!បាទអ៊ុំ ចុះយាយតាខាងឪពុកនឹងអ៊ុំមានស្គាល់ឈ្មោះគាត់ដែរទេអ៊ុំ?

ខៈ  អើរអត់ចងចាំទេក្មួយ

កៈ  ចុះយាយតាខាងម្ដាយវិញអ៊ុំមានស្គាល់ឈ្មោះគាត់ដែរទេ?

ខៈ  អត់មានទេ

កៈ ចឹងអត់មានស្គាល់ទាំងអស់ណាអ៊ុំ?

ខៈ  បាទអត់មានស្គាល់ទេ

កៈ
ប៉ុន្តែដូចជាយាយតាខាងឪពុកនឹងយាយតាខាងម្ដាយនឹងគាត់កើតនៅណាដែរអ៊ុំមានដឹងទេ?

ខៈ
អត់ដឹងទេបើនិយាយអោយចំទៅអ៊ុំនិយាយអោយត្រង់ទៅឪពុកម្ដាយនឹងសុទ្ធកូនកាត់ទាំងអស់នឹង

កៈ  អូ!គាត់ជាកូនកាត់ហោសអ៊ុំ គាត់កូនកាត់អីគេដែរទៅអ៊ុំ?

ខៈ  គាត់កូនកាត់វៀតណាម

កៈ  គាត់ជាកូនកាត់វៀតណាមនឹងទាំងអស់នឹងហោសអ៊ុំ?

ខៈ  បាទនឹងហើយកាត់

ក៖ អូ!បាទចុះអ៊ុំមករស់នៅភ្នំពេញនឹងយូរដែរនៅអ៊ុំ?

ខ៖ ខ្ញុំមកនៅតាំងពីជំនាន់សីហានុ

ក៖ តាំងពីជំនាន់សីហានុនឹងអូចឹងវាយូរដែរណាអ៊ុំ?

ខ៖ ចុះកាលពីរដ្ឋប្រហារនៅឆ្នាំ1970នោះ

ក៖ បាទអ៊ុំម៉េចទៅ?

ខ៖ នៅសាលាបឹងត្របែកនឹងមិនបាតុកម្មកាលណុងខ្ញុំនៅតូចនឹងដែរ

ក៖ បាទអ៊ុំចឹងហោសអ៊ុំ?

ខ៖ ហ៎ា!ណុងនៅតូចស្អីគេកាលណុង

ក៖ អ៊ុំរៀនធំហើយណាអ៊ុំ?

ខ៖ កាលណុងរៀងធំហើយនឹង

ក៖ អូ!បាទចុះអ៊ុំមានបងប្អូនរឺមួយក៏កូនចៅណាដែរទៅរស់នៅក្រៅប្រទេសទេអ៊ុំ?

ខ៖ អត់មានទេ

ក៖ នៅថៃ វៀតណាម ចិន ឡាវអីក៏អត់មានដែរហោសអ៊ុំ?

ខ៖ មាននៅវៀតណាមប៉ុន្តែបែកគ្នាតាំងពីនៅឆ្នាំ1975ហោសឥឡូវនឹងអត់

ក៖ ចុះគាត់នឹងនរណាគេដែរអ៊ុំជាប្អូនរបស់អ៊ុំនឹងរឺនរណាគេដែរអ៊ុំ?

ខ៖ ខាងក្មួយខាងម្តាយរបស់ខ្ញុំនឹងហាសហើយក៏ត្រូវជាក្មួយរបស់ខ្ញុំនឹង

ក៖ អូ!បាទៗអ៊ុំចឹងក្មួយរបស់អ៊ុំនឹងចឹងត្រូវជាចៅរបស់ម្តាយរបសើអ៊ុំហើយណាអ៊ុំ?

ខ៖ អត់ទេវាហៅខ្ញុំ

ក៖ ហោថាពូមែនអ៊ុំ?

ខ៖ ហៅពូអ្នកខ្លះហៅបងទៅកាលពីឆ្នាំ1975នឹងគេជំលាសទៅនឹង

ក៖ បាទអ៊ុំបាទ?

ខ៖  គេជំលាសទៅនឹងទៅនៅរហូតទៅហើយខ្ញុំនឹងនៅតរហូតនឹង

ក៖  ប៉ុន្តែក្មួយរបស់អ៊ុំនៅវៀតណាមនឹងគេធ្វើអីគេដែរនៅណុងអ៊ុំ អ៊ុំមានដឹងទេ?

ខ៖  ខ្ញុំអត់ដឹងដែរនឹងខ្ញុំមិនដែរទៅលេងផងនឹង

ក៖  ចឹងយើងខានទាក់ទងគ្នាយូរហើយណាអ៊ុំ?

ខ៖  អត់មានទេដែរផង

ក៖  ចឹងអត់មានដែរទាក់ទងគ្នាផងហោសអ៊ុំ?

ខ៖  អត់ទេ

ក៖  អូ៎!បាទអ៊ុំ ចុះពីមុននឹងភរិយារបស់អ៊ុំនឹងមានឈ្មោះអីគេដែរអ៊ុំ?

ខ៖  ឈ្មោះឃីម

ក៖  ឈ្មោះឃីម ចុះឈ្មោះស្អីគេឃីមដែរទៅអ៊ុំ?

ខ៖  គាត់ឈ្មោះម៉ៅឃីម គាត់នៅកំពង់ចាម

ក៖  ឈ្មោះម៉ៅ ឃីម ប៉ុន្តែគាត់ឥឡូវនឹងនៅកំពង់ចាមនឹង?

ខ៖  គាត់ស្លាប់បាត់ហើយនឹង

ក៖  គាត់ស្លាប់បាតហើយហោសអ៊ុំ
អូ៎!ចុះអ៊ុំមានចងចាំថាអ៊ុំបានរៀបអាពាហ៍ពិពាហ៍ជាអ៊ុំស្រីនឹងនៅថ្ងៃខែ ឆ្នាំណាដែរអ៊ុំ?

ខ៖  ខ្ញុំរៀបការជាមួយយាយនឹងនៅឆ្នាំ1967

ក៖  ចឹងនៅឆ្នាំ1967ណាអ៊ុំ?

ខ៖  នឹងហើយការបាន3ឆ្នាំនឹងលុនណុលបានទំលាក់សម្តេច

ក៖  បាទអ៊ុំ
ចុះនៅពេលដែរអ៊ុំរៀបអាពាហ៍ពិពាហ៍ជាមួយអ៊ុំស្រីនឹងដូចជាអ៊ុំជាអ្នករៀបចំដោយចិត្តឯង
រឺមួយក៏ឪពុកម្តាយរបស់អ៊ុំគាត់ជាអ្នករៀបអោយដែរអ៊ុំ?

ខ៖
អត់ទេកាលណុងនិយាយអោយត្រង់ទៅអ៊ុំក្រនឹងគេក៏ក្រដៃរយើងស្រលាញ់ចិត្តនឹងចិត្តទេ

ក៖ អូ៎!ចឹងទេហោសអ៊ុំ?

ខ៖ បាទនឹងហើយចឹង

ក៖ ប៉ុន្តែពេលដៃរការនឹងដូចជាមានជាជំនូនទេអ៊ុំ
តើអ៊ុំមានជូនអីទៅអ៊ុំស្រីទេដូចថាលក្ខណះថាបណ្ណាការអីចឹងហាសអីអ៊ុំ?

ខ៖ អត់ទេគេអត់ទារផង

ក៖ ចឹងអត់មានទេណាអ៊ុំ?

ខ៖ អត់ទេគ្រាន់តែភ្ជុំអីចឹងទៅលេងចឹងទៅ

ក៖ យើងអោយរបស់របរអីចឹងទៅ?

ខ៖ បាទនឹងចឹង

ក៖ អូ៎!លក្ខណះថាយើងទៅញ៉ាំអី ទៅធ្វើអី រឺមួយក៏ទៅជូនលុយអីចឹងហោស?

ខ៖
បាទនឹងយើងក្រគេគ្មានទារអីទេឪពុកម្តាយខាងគេនឹងយើងទៅលេងទៅទៅលេងបន្តិចបន្តួចទៅ ហើយនឹងទៅជូនលុយអីតិចតួចទៅហើយ

ក៖ អូបាទអ៊ុំចុះលក្ខណះថាយើងស្រលាញ់គ្នាចិត្តនឹងចិត្តយើងមិនចាំបាច់ខ្វល់អីទេណាអ៊ុំ?

ខ៖ បាទៗនឹងហើយ

ក៖ បាទអ៊ុំចុះអ៊ុំអាចប្រាប់ពីពេលដៃរអ៊ុំស្រលាញ់គ្នាជាមួយអ៊ុំស្រីពេលណាដៃរទេអ៊ុំ?

ខ៖ ជួបគាត់នឹងនៅឆ្នាំ1967នឹង

ក៖ ចុះហេតុអីបានអ៊ុំស្រលាញ់គ្នា ហើយអស់រយះពេលប៉ុន្មានឆ្នាំដៃរអ៊ុំចូលស្តីដណ្តឹងគាត់?

ខ៖ មូលហេតុនឹងគេមាននិស្ស័យ

ក៖ ជានិស្ស័យណាអ៊ុំ?

ខ៖ ខ្ញុំនៅភ្នំពេញហើយគាត់នៅកំពង់ចាម ហើយគាត់មានបងប្អូនជីដូនមួយមកស្រលាញ់គាត់

ក៖ អូ៎!បាទអ៊ុំបាទ?

ខ៖ ហើយចូលស្ដីដណ្ដឹងនឹងភរិយាហើយគាត់ក៏មិនព្រមឯម៉ែឪនឹងបង្ខំពេកគាត់ក៏ព្រមទៅពេលដែររៀប ទៅនឹងគេលួចវេចមួយបង្វេចនឹងមកភ្នំពេញនឹងមកជួបនឹងខ្ញុំហាស

ក៖ ហាសចឹងគាត់បង្ខំចិត្តដើម្បីមកជួបអ៊ុំវិញគាត់អត់ចង់យក?

ខ៖ បងប្អូនជីដូនមួយនឹងគាត់អត់ចង់យកទេ

ក៖ អូ៎!ចឹងហោសអ៊ុំ?

ខ៖ គាត់ប្រកែកថាគាត់មិនយកប៉ុន្តែឪពុកម្ដាយគាត់ជាអ្នកទុកដាក់អោយចឹងទៅណាស់

ក៖ បាទអ៊ុំចឹងបាទ?

ខ៖ ហើយវាព្រមទៅព្រមៗដល់ពេលដែរថ្ងៃការនឹងបានវេចបង្វេចទៅភ្នំពេញនឹង

ក៖ ប៉ុន្តែឪពុកម្ដាយរបស់គាត់នឹងអត់ថាអីទេ?

ខ៖ គាត់អត់ថាអីទេ

ក៖ ដល់ពេលដែរការជាមួយគាត់ហើយក៏ម្ដាយឪពុកគាត់អត់ថាអីដែរ?

ខ៖ អត់ថាអីទេខ្ញុំគ្មានការទេបើស្រលាញ់គ្នាចិត្តនឹងចិត្តនឹងបើក្រដល់តែមានកូនមួយ

ក៖ បាទអ៊ុំបាទនឹង?

ខ៖ មានកូនមួយនឹងនៅកំពង់ចាមនៅកំពង់ចាមនឹងឈ្មោះអាហេងនឹង កាលពីវាមកនឹងវាពិបាកចិញ្ចឹម ពេកនឹងខ្ញុំដឹកវាទៅវត្តស្ទឹងមានជ័យនឹង

ក៖ អូ៎!បាទអ៊ុំនៅវត្តស្ទឹងមានជ័យណាអ៊ុំ?

ខ៖ បាទអោយលោកដាក់ឈ្មោះអោយនឹងដាក់ឈ្មោះសេង សុខហេង ហើយខ្ញុំនឹងឈ្មោះសេង ខុន

កៈ អូ៎!ចឹងដាក់ត្រកូលខាងតាណអ៊ុំ?

ខៈ បាទដាក់ខាងឪពុកនឹង

កៈ បាទអ៊ុំចឹងនេះជាអាពាហ៍ពិពាហ៍ដែរអ៊ុំបានរៀបជាមួយអ៊ុំស្រីនឹង?

ខៈ អត់មានរៀបទេគ្រាន់តែយើងស្រលាញ់ចិត្តនឹងចិត្តទេនឹង

កៈ អូ៎!យលងស្រលាញ់គ្នាចិត្តនឹងចិត្ត?

ខៈ ដល់ពេលដែរមានកូនមួយបានទៅ

កៈ បាទអ៊ុំ ចុះអ៊ុំមានចេះសរសេររឺមួយក៏ចេះអានអក្សរខ្មែរដែរទេអ៊ុំ?

ខៈ អត់ទេអក្សរអីមួយក៏មិនចេះដែរនឹងុះបើមិនបានរៀនសូត្រផងនឹងក្មួយ

កៈ អូ៎!ចឹងមានន័យថាអ៊ុំអត់ដែរបានរៀនសូត្រផងហោសអ៊ុំ?

ខៈ បាទៗនឹងហើយ

កៈ អូ៎!ចុះដូចជាអ៊ុំមានចេះភាសាអីផ្សេងដែរទេអ៊ុំ ភាសាចិន វៀតណាម ថៃអីអ៊ុំមានចេះទេ?

ខៈ បើចេះនិយាយខ្ញុំចេះប៉ុន្តែបើជ្រៅជ្រះនឹងអត់មានចេះទេ

កៈ ចុះអ៊ុំមានចេះភាសាអីគេដែរអ៊ុំ?

ខៈ ខ្ញុំចេះភាសារាល់ថ្ងៃនឹងបើនិយាយពីចេះវិញវាមិនសូវជាចេះប៉ុន្មានទេនឹង
តែបើគេនិយាយវិញស្តាប់ បានដែរ

កៈ ភាសាវៀតណាមមែនទេអ៊ុំ?

ខៈ ប៉ុន្តែយើងនិយាយនឹងស្តាប់មិនសូវបានទេ

កៈ ប៉ុន្តែភាសាវៀតណាមមែនទេអ៊ុំ?

ខៈ មានភាសាវៀតណាមក៏ដោយ
រឺក៏ភាសាចិនក៏ដោយខ្មែរក៏ដោយអ៊ុំថាឈឺនេះតើបានអ៊ុំមកនៅជាមួយ កូននឹងហាស

កៈ ចឹងមានន័យថាអ៊ុំមានចេះ3ភាសាណអ៊ុំ?

ខ៖  បាទនឹងហើយ

ក៖  អ៊ុំចេះចិន វៀតណាម ខ្មែរ ចុះអ៊ុំធ្លាប់មានមិត្តភក្តិណាដែរស្និទ្ធិស្នាលធំធាត់មកជាមួយគ្នាដែរទេអ៊ុំ?

ខ៖  ហីមានដែរក្មួយតាំងពីឆ្នាំ1975នឹងមកបែកគ្នារហូតអត់ដែរបានជួគ្នាទេនឹង

ក៖  អូ៎!បាទអ៊ុំប៉ុន្តែដូចជាមានច្រើនដែរទេអ៊ុំ?

ខ៖  មានច្រើនដែរនឹង

ក៖  ដូចជាអ៊ុំអាចប្រាប់ឈ្មោះមួយចំនួនដែរអ៊ុំអាចចាំបានទេអ៊ុំ?

ខ៖  គេមានឈ្មោះសុទ្ធតែឈ្មោះចិន នឹងឈ្មោះវៀតណាមអីចឹងហោស

ក៖  ប៉ុន្តែអ៊ុំអាចប្រាប់ឈ្មោះបន្តិចបានទេថាពួកគាត់មានឈ្មោះអីគេខ្លះដែរទៅអ៊ុំ?

ខ៖  មានឈ្មោះច្រើនណាស់ក្មួយអើយរៀបរាប់មិនអស់ទេក្មួយអើយ

ក៖  ចឹងហោសអ៊ុំ ចុះប៉ុន្តែអ៊ុំមានចងចាំអនុស្សាវរីយ៍អីកាលពីនៅក្មេងជាមួយគាត់ដែរទេអ៊ុំធ្លាប់ដើរអីគេខ្លះដែរចឹងហាសជាមួយមិត្តភក្តិជិតស្និទ្ធិរបស់អ៊ុំហាស ធ្លាប់មានអនុស្សាវរីយ៍អីគេដែរអ៊ុំគិតថាអ៊ុំចងចាំមិនភ្លេចដែរទេ?

ខ៖  ហេ៎!កាលណុងចុះក្មួយឯងគិតមើលតាំងពីនៅវ័យកុមារហោសរហូតមកដល់ឥឡូវនឹងអស់ប៉ែតសិប ប៉ុន្មានឆ្នាំដែរហើយនឹង

ក៖  អស់84ឆ្នាំហើយអ៊ុំរឺ83ឆ្នាំហើយនឹង?

ខ៖  នៅ84ឆ្នាំនៅឆ្នាំនឹង84ឆ្នាំនឹង

ក៖  បាទអ៊ុំប៉ុន្តែអ៊ុំមានចងចាំថាទៅស្រែរឺមួយក៏ទៅដើរលេងអីជាមួយគ្នាដែរចឹងហាសអ៊ុំលក្ខណះថាទៅមើលល្ខោនអីជាមួយគ្នាដែរទេអ៊ុំ?

ខ៖  អត់មានទេ

ក៖  ប៉ុន្តែអ៊ុំធ្លាប់បានធ្វើអីគេខ្លះជាមួយពួកគាត់ដែរអ៊ុំ?

ខ៖ បាទថាម៉េច?

ក៖ អ៊ុំធ្លាប់បានធ្វើអីគេជាមួយមិត្តភក្តិរបស់អ៊ុំដែរទៅអ៊ុំ?

ខ៖ អត់ទេអ៊ុំកាលពីតូចនឹងអ៊ុំដើរតែលក់នំប៉ុងអីនឹងចិញ្ចឹមជីដូនជីតា
ដល់ពេលដែរធំឡើងនឹងនៅតែរត់តុ

ក៖ អូ៎!ចឹងហោសអ៊ុំណា?

ខ៖ បាទលក្ខណះថារត់តុបាយអីនឹងនៅមុខវត្តឧណ្ណាលោមយើងនេះផ្ទះលេខ185
នៅផ្លូវទី3នឹង

ក៖ បាទអ៊ុំចុះអ៊ុំធ្លាប់ទៅធ្វើការងារនៅវាលស្រែដែរទេអ៊ុំ
លក្ខណះស្រែចំការហាសអ៊ុំធ្លាប់ទៅធ្វើនៅណុងទេ?

ខ៖ អត់ដែរទេ

ក៖ អត់ទេណាអ៊ុំណាចុះលក្ខណះ?

ខ៖ បើជំនាន់អាពតនឹងធ្វើ

ក៖ ចឹងហោសអ៊ុំធ្វើ?

ខ៖ នៅក្នុង3ឆ្នាំ 8ខែ 20ថ្ងៃនឹងអ៊ុំធ្វើក្បួររាស់ហើយ ដកស្ទូងវាប្រើ ច្រូតអីនឹងវាប្រើ

ក៖ បាទអ៊ុំចុះជុំធ្លាប់អាជីវកម្មរកស៊ីលក់ដូរអីទេ?

ខ៖ អត់មានទេនឹងអត់ទេក្មួយ

ក៖ ចុះចិញ្ចឹមមាន់ ទា ជ្រូក គោអីនឹងក៏អ៊ុំអត់មានដែរ?

ខ៖ អត់មានទេមានតែកូនចិញ្ចឹមនឹង

ក៖ អូ៎!បាទអ៊ុំ
ចុះអ៊ុំគិតថាជីវិតរបស់អ៊ុំនឹងមានការផ្លាស់ប្តូរអីគេខ្លះដែរអ៊ុំតាំងពីក្មេងរហូតមកដល់ពេលនេះ
ហាសអ៊ុំ?

ខ៖ អត់ទេនៅតែវេទនានៅតែក្រចឹងរហូតនឹង

កៈ ប៉ុន្តែសុខភាពអីនឹងយ៉ាងម៉េចដែរអ៊ុំ?

ខៈ សុខភាពនឹងអត់ដែរឈឺអត់ដែរអីទេ

កៈ អូ៎!អ៊ុំសុខភាពល្អហាសណាអ៊ុំ?

ខៈ
តាំងពីកើតពោះម៉ាយរហូតមកដល់ឥឡូវនឹងប្រាប់ក្មួយអោយត្រង់សូម្បីតែទឹកនោមផ្អែមនឹងក៏អត់ មានដែរនឹង ហើយឈាមក៏អត់មើល

កៈ អូ៎!បាទអ៊ុំចឹង?

ខៈ អ៊ុំតែឈឺខ្លាំងចឹងទៅស្មាទោបាទស្រាសយើងនឹងដាក់កន្លះលីត្រចឹងទៅ
ហើយដេកដណ្ដប់ភួយនឹង

កៈ ជាក៏លែងអីដែរហើយណាអ៊ុំ?

ខៈ លែងមានអីទៀតហើយនឹង

កៈ អូ៎!ឡូយដែរអ៊ុំ ចុះម្ហូបអីដែរអ៊ុំចូលចិត្តពិសារដែរអ៊ុំ
តាំងពីក្មេងរហូតមកដល់ពេលនេះអ៊ុំនៅតែ ចូលចិត្តហាសអ៊ុំ?

ខៈ ម្ហូបដែរចូលចិត្តជាងគេនឹងប្រហុកចិញ្រ្ចាំជាមួយសាច់ជ្រូកនឹងពងទាទេនឹង

កៈ ចឹងណាអ៊ុំ?

ខៈ បាទនឹងហើយ

កៈ បាទចុះល្បែងប្រជាប្រិយ៍អីដែរអ៊ុំចូលចិត្តលេងដែរអ៊ុំ ដូចជាចោលឈូង លាក់កន្សែង
បោះអង្គុញ ទាញព្រាតហាសអ៊ុំ?

ខៈ ចូលចិត្តលេងលាក់កន្សែង

កៈ ចុំលេងស្តេចចង់លេងដណ្ដើមស្លឹកឈើអីអ៊ុំចូលចិត្តលេងទេ?

ខៈ ហើយនឹងលេងចោលឈូង

កៈ អូបោះឈូងណាអ៊ុំ?

ខ៖ ហើយនឹងលេងលាក់កន្សែងស្រណុកវៃគូថហាស

ក៖ ចុះដណ្ដើមស្លឹកឈើអីនឹងអ៊ុំចុលចិត្តលេងទេ?

ខ៖ អត់ទេនឹង

ក៖ អូ៎!បាទអ៊ុំ ចុះអ៊ុំច្រៀងពីមុនទេ អ៊ុំចេះច្រៀងនឹងចូលចិត្តច្រៀងទេ?

ខ៖ ហ៊ឺចេះច្រៀងដែរនឹង

ក៖ ចឹងអ៊ុំចេះច្រើងដែរហោសអ៊ុំ?

ខ៖ ច្រៀងនឹងចេះកាលពីច្រៀងជំនាន់លោកស៊ិនស៊ីសាម៉ុតហាស

ក៖ បាទអ៊ុំបាទ?

ខ៖ ចេះអានឹងក៏ចេះដែរ
ហើយចេះរៀនច្រៀងក្រោយនឹងនិយាយទៅចេះច្រៀងបានច្រើនដែរណាស់

ក៖ បាទអ៊ុំចូលចិត្តស្ដាប់បទចំរៀងទេអ៊ុំ?

ខ៖ បាទថាម៉េច?

ក៖ បាទអ៊ុំចូលចិត្តស្ដាប់បទចំរៀងដែរទេអ៊ុំ?

ខ៖ ចូលចិត្តដែរតើនឹង

ក៖ បទបុរាណរឺមួយក៏បទបុរាណដែរអ៊ុំចូលចិត្តដែរ?

ខ៖ ខ្ញុំចូលចិត្តបទបុរាណនឹង

ក៖ ចឹងហោសអ៊ុំណា
ចុះអ៊ុំគិតថាមាននរណាម្នាក់នៅក្នុងក្រុមគ្រួសាររបស់អ៊ុំនឹងចេះលេងឧបករណ៍ភ្លេង
ដែរទេអ៊ុំ?

ខ៖ អត់មានទេ

កៈ ចឹងអត់មានទេណាអ៊ុ
ចុះផ្ទះរបស់អ៊ុមានលក្ខណៈបែបនណាដែរតាំងពីក្មេងរហូតមកដល់ពេលនេះ
ហាសតាំងពីក្មេងនឹងផ្ទះយ៉ាងម៉េច?

ខៈ កាលពីផ្ទះហានៅបឹងត្របែកនឹងមើផ្ទះជញ្ជាំងក្តារប្រកស័ង្កសី

កៈ អូ៎!បាទអ៊ុំបាទ?

ខៈ នៅអីនៅក្រោយរដ្ឋត្រកទឹកនៅជិតចំការដូងនោះ

កៈ អូ៎!បាទអ៊ុំចុះផ្ទះរបស់អ៊ុំនឹងនរណាគេជាអ្នកធ្វើដែរអ៊ុំ
អ៊ុំជួលគេរឺមួយក៏អ៊ុំធ្វើដោយខ្លួនឯងដែរអ៊ុំ?

ខៈ អត់ទេផ្ទះដោយខ្លួនឯងនឹង

កៈ ប៉ុន្តែអ៊ុំជួលគេធ្វើរឺយ៉ាងម៉េចដែរអ៊ុំ?

ខៈ អត់ទេឪពុកម្តាយជាអ្នកធ្វើនឹង

កៈ អូ៎!គាត់ចេះធ្វើផ្ទះហោសអ៊ុំ?

ខៈ បាទគាត់ចេះ

កៈ គាត់ចេះធ្វើមកពីនរណាគេដែរអ៊ុំ?

ខៈ គាត់ជាជាងឈើនឹងជាងផ្ទះអីនឹងសំណង់ក៏ចេះដែរនឹង

កៈ បាទអូ៎!ឡូយ ចុះអ៊ុំគិតថាជំនាញអីដែរអ៊ុំគិតថាអ៊ុំចេះស្ទាត់ជំនាញដែរអ៊ុំ?

ខៈ ជំនាញអ៊ុំសព្វថ្ងៃនឹងហោស?

កៈ បាទអ៊ុំបាទ?

ខៈ អូ៎!អ៊ុំស្អីក៏អ៊ុំធ្វើដែរកាលបីអ៊ុំនៅកំលាំងនឹងធ្វើជាងសំណង់នឹង

កៈ អូ៎!អ៊ុំចូលចិត្តធ្វើជាចាងសំណង់ហោសអ៊ុំ?

ខៈ បាទនឹងហើយ

កៈ ចុះលក្ខណៈធ្វើផ្តៅ កូរស្ករត្នោតរឺមួយក៏ធ្វើជាកន្ទេលអីអ៊ុំមានចេះទេនឹង?

ខ៖  អត់មានទេនឹង

ក៖  អត់ចេះទេអ៊ុំណា?

ខ៖  បាទអត់ចេះទេនឹង

ក៖
ចុះអ៊ុំអាចប្រាប់ពីពេលដំបូងពីពេលណាដែរអ៊ុំគិតថាពិបាកដំបូងពីក្មេងរហូតមកដល់ពេលនេះហាស?

ខ៖  បាទនឹង

ក៖ ពេលណាដែរអ៊ុំ?

ខ៖  នៅក្នុងពីកើតដឹងក្តីមកនឹងនៅជំនាន់ពលពតនឹងពិបាកជាងគេហើយនឹង

ក៖  នៅជំនាន់ពលពតណាអ៊ុំ ចុះពេលណុងគេអោយអ៊ុំធ្វើអីគេខ្លះដែរទៅអ៊ុំ?

ខ៖  គេអោយទៅភ្ជួរទៅគេប្រើហូបបាយមួយពេលចឹងទៅ នឹងបបរតែពីរស្លាបព្រាទេនឹង

ក៖  បាទអ៊ុំចឹង?

ខ៖  នៅក្នុងសហាករនឹងគេដាក់តែ4កំប៉ុងទេអានឹងខ្វយើញផ្ទាល់ភ្នែក

ក៖  បាទអ៊ុំចឹងហោស?

ខ៖
ហើយអំបិលករាប់មួយកូនចានហើយគេសួរថាកាលពីជំនាន់ណុងគេហៅថាសាក់មះមិត្តហាស ថាសាក់មះមិត្តឆ្ងាញ់ទេ ឆ្ងាញ់ហើយបបររាវឃ្លោកចឹង

ក៖  ប៉ុន្តែពេលណុងអ៊ុំគេអោយទៅនៅណាដែរទៅ?

ខ៖  គេជំលាសទៅនៅកំពង់ចាមនឹង

ក៖  ប៉ុន្តែគេអោយអ៊ុំធ្វើអីគេដែរទៅអ៊ុំ?

ខ៖  នៅធ្វើស្រែ នឹងលើទំនុបជីកប្រឡាយ

ក៖  អូ!ប៉ុន្តែអ៊ុំមាននៅគ្នាច្រើនមែនដែរទេអ៊ុំ?

ខ៖ បាទថាម៉េច?

ក៖ មាននៅជាគ្នាច្រើនមែនអ៊ុំ?

ខ៖ មានគ្នាច្រើនមួយសហករគេនឹងមានប៉ុន្មានគ្រួសារចឹងទៅនៅប្រមូលផ្តុំចឹងទៅ

ក៖ ប៉ុន្តែដូចជាពេលណុងអ៊ុំនៅអាយុប៉ុន្មានដែរអ៊ុំ ពេលដែរចូលជំនាន់ពលពតនឹង?

ខ៖ យើងអាយុច្រើនដែរនឹងវានៅតែប្រើអ៊ុំនឹង

ក៖ ប៉ុន្តែពេលណុងអ៊ុំមានកូនចៅហើយណាអ៊ុំ?

ខ៖ មានតែកូនបងមួយនឹងឈ្មោះអាហេងនឹង

ក៖ អូ៎!បាទចុះរហូតទាល់តែដាច់ពលពតនឹងអ៊ុំមានការលំបាកអីផ្សេងទេអ៊ុំ?

ខ៖ កាលពីដាច់ពលពតនឹងយើងវារកស៊ីខ្លួនឯងនឹង វាគ្រាន់បើជាងជំនាន់ពលពតនឹង

ក៖ ប៉ុន្តែមុនដាច់ពលពតភ្លាមៗនឹងជីវភាពយើងនៅតែយ៉ាប់ដដែរមែនទេអ៊ុំ?

ខ៖ នៅតែពិបាកនឹងនៅធ្វើជាកម្មករទៅនឹងធ្វើសំណង់អោយគេនឹង

ក៖ អូ៎!បាទអ៊ុំ ចុះអ៊ុំឆ្លងកាត់ការលំបាកមួយនឹងដោយរបៀបណាដែរអ៊ុំ?

ខ៖
ហ៉ា!បើនិយាយពីរៀបរាប់វិញមិនអស់ទេក្មួយវាពិបាកមែនទែននឹងតាំងពីកើតនៅក្នុងជីវិតរបស់អ៊ុំនេះ តែសំណាងដែរទឹកដោះឪពុកម្តាយវាថ្លៃនឹងអ៊ុំអត់ចេះឈឺស្អាត់ទេ

ក៖ អូ៎!ចឹងអ៊ុំអត់ចេះឈឺទេណាអ៊ុំ?

ខ៖ បាទនឹងហើយ

ក៖ ចុះជំនាន់ពលពតនឹងក៏អ៊ុំអត់ចេះឈឺដែរ?

ខ៖ អត់មានទេ

ក៖ អូ៎!ល្អដែរអ៊ុំ
ចុះអ៊ុំគិតថាពេលណាដែរអ៊ុំគិតថាជាពេលដែរសប្បាយនៅក្នុងឆាកជីវិតរបស់អ៊ុំដែរចឹងហាសអ៊ុំ គិតថាពេលណាដែរអ៊ុំ?

ខ៖
បើតាមដែរខ្ញុំនឹកឃើញមកនឹងតាំងពីសង្គមមកនឹងដែរសប្បាយជាងគេនឹងមានតែសម្ដេចឪ
ទេនឹង ជាបិតាជាតិ

ក៖ គាត់ធ្វើអីគេខ្លះដែរទៅអ៊ុំ?

ខ៖ បាទម៉េចវិញ?

ក៖ គាត់ធ្វើអីគេខ្លះដែរទៅអ៊ុំ?

ខ៖ ហ៎!យើងដើររកស៊ីរាំលេងសប្បាយអីការងារអីនឹងវាធម្មតាហើយនឹង

ក៖ បាទអ៊ុំចឹង?

ខ៖ ហើយកាលពីជំនាន់ណុងគ្មានចោរប្លន់អីទេ
អោយតែមានកាតខ្មៅមួយដើរទៅប៉ូលីសគេឆែកទៅ ហុចអោយគេទៅហើយនឹង

ក៖ បាទអ៊ុំ
ចុះអ៊ុំគិតថាតាំងពីក្មេងហាសអ៊ុំធ្លាប់មានក្ដីសង្ឃឹមថាពេលដែរធំឡើងនឹងអ៊ុំចង់ធ្វើអីដែរទេ?

ខ៖ ហ៎!សង្ឃឹមថាពេលដែរធំឡើងនឹងគ្រាន់មានលុយមានកាក់អី មានបាននឹងគេ
ដល់ពេលដែរធំឡើងនឹងនៅតែក្រនឹងក្ទួយ
តាំងពីដឹងក្ដីរហូតដល់ចំណាស់នឹងគេនឹងមិនដែរបានសប្បាយ នឹងគេទេនឹង

ក៖ ចុះអ៊ុំធ្លាប់គិតថាពេលដែរធំឡើងនឹងអ៊ុំចង់ធ្វើជាគ្រូពេទ្យ
រឺគ្រូបង្រៀនរឺមួយក៏លក្ខណៈដូចជាធ្វើជាអ្នក ជំនាញលក់ដូរអីមួយចឹងហាស?

ខ៖ ធ្លាប់គិតដែរប៉ុន្តែធ្លាប់គិតមួយថាយើងទៅរៀនចឹងម្ដាយឪពុកយើងក្រ
ហើយបើយើងចង់ធ្វើជា វិជ្ជបណ្ឌិតអីនឹងទាល់តែយើងរៀន

ក៖ បាទត្រូវអ៊ុំបាទ?

ខ៖ ចុះបើយើងមិនរៀនចឹងបានអីមិននៅជាកម្មករលីសែងចឹងទៅ

ក៖ នឹងត្រូវអ៊ុំទាល់តែយើងខំប្រឹងរៀនដែរ?

ខ៖ បាទមួយគ្រួសារនឹងមើលមានបងប្អូនច្រើនដែរនឹងប៉ុន្តែខាងឪពុកបង្កើតនេះ មានតែបងទេដែរក្រជាង គេនឹងបងគេវាត្រូវអោយប្អូនរៀនសូត្រ ប៉ុន្តែបងគាត់សុខចិត្តពិបាក

ក៖ បាទអ៊ុំបាទ ចុះបើសិនជាចង់អោយអ៊ុំផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗៗនឹងតើអ៊ុំចង់ផ្តែផ្តាំអីទៅពួកគាត់ដែរអ៊ុំ?

ខ៖ ចង់ផ្តាំពាក្យចុងក្រោយនិយាយទូទាំងអស់តែម្តងនឹង

ក៖ និយាយទាំងកូនចៅរបស់អ៊ុំអីនឹង?

ខ៖ និយាយទាំងកូនចៅអីនឹងទាំងអស់នឹងអោយធំឡើងនឹងអោយដឹងគុណឪពុកនឹងម្តាយ

ក៖ បាទចឹងត្រូវអ៊ុំ?

ខ៖ ហើយជាពិសេសនឹងជីដូនជីតាញាតិ7សន្តានធ្វើយ៉ាងម៉េចអោយល្អ អោយចិត្តមេត្តាស្អាត

ក៖ បាទអ៊ុំបាទចុះ?

ខ៖ រឿងអ្វីៗៗដែរអាក្រក់នឹងមិនបាច់ទុកបោះចោល

ក៖ ចុះអ៊ុំគិតថាចង់អោយកូនចៅជៀសរៀងអីគេដែរអ៊ុំ អំពើមួយដែរអត់ល្អហាស?

ខ៖ ជៀសរៀងនឹងទី1នឹងកុំអោយប៉ះពាល់ដល់គ្រឿងញៀននឹង ទី2នឹងកុំអោយមានដៃមានជើងកាប់សំលាប់ អោយយើងធ្វើតែល្អ

ក៖ បាទអ៊ុំ ចុះអ៊ុំមានអីដែរចង់ផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗៗទៀតអត់អ៊ុំ?

ខ៖ គ្រាន់តែអ៊ុំផ្តែផ្តាំតែប៉ុណ្ណឹងទេអោយវាជួយ

ក៖ បាទអ៊ុំ ចឹងជាចុងក្រោយខ្ញុំអរគុណច្រើនអ៊ុំដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់អ៊ុំ ហើយខ្ញុំនឹងដាក់ ការសំភាសន៍មួយនឹងទៅក្នុងវេបសាយរបស់សាលាណាអ៊ុំ

ខ៖ បាទនឹងហើយ

ក៖ បាទចឹងអរគុណច្រើនណាស់អ៊ុំ៕៕៕